# ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្ត

**វគ្គបណ្តុះបណ្តាលមន្ត្រីការិ.ច្រកចេញចូលតែមួយ និងការិ.ប្រជាពលរដ្ឋ**

**រៀបចំដោយ÷ នាយកដ្ឋានមុខងារ និងធនធាន**

**អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ**

# មាតិកា

១. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

២. គោលការណ៍នៃការបែងចែក

៣. ប្រភពប្រាក់រង្វាន់លើកទឹកចិត្ត

៤. របៀបនៃការបែងចែក

## ១. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

- ប្រកាសអន្តរក្រសួងលេខ១៤៣៤៣ ប្រក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិកាលើកទឹកចិត្តលើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សេចក្តីណែនាំលេខ០១៨ សណន ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិលើការផ្តល់សេវារដ្ឋបាល

## ២. គោលការណ៍នៃការបែងចែក

- ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនដល់មន្ត្រី និងបុគ្គលិករដ្ឋបាលស្រុក ត្រូវផ្អែកលើគោលការណ៍ដូចខាងក្រោម៖
  - ✓ តម្លាភាព
  - ✓ សមធម៌ និង
  - ✓ ផ្អែកតាមគុណសម្បត្តិការងារ។
- ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តត្រូវធ្វើរៀងរាល់ដំណាច់ខែនីមួយៗ
- ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តត្រូវអនុម័តដោយក្រុមប្រឹក្សាស្រុក

# ៣. ប្រភពប្រាក់រង្វាន់លើកទឹកចិត្ត

ប្រភពប្រាក់រង្វាន់លើកទឹកចិត្ត រួមមាន ៖

១. ចំណែកប្រាក់រង្វាន់ដែលបានមកពីការផ្ដល់សេវារដ្ឋបាលរបស់រដ្ឋបាលស្រុក

២. ចំណែកប្រាក់រង្វាន់ដែលបានមកពីការបែងចែកពីក្រសួងស្ថាប័ន មន្ទីរ អង្គភាពផ្សេងៗ

៣. ចំណែកប្រាក់រង្វាន់ដែលបានមកពីការបែងចែកពីថ្នាក់រដ្ឋបាលផ្សេងទៀត

## ៤. របៀបនៃការបែងចែក

- អភិបាលស្រុកត្រូវលើកសំណើអំពីការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនក្រុមប្រឹក្សារបស់ខ្លួន ដើម្បីអនុម័ត។
- ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវគោរពតាមការកំណត់ដូចខាងក្រោម ៖

  ក. ប្រាក់រង្វាន់សម្រាប់ឧបត្ថម្ភជូនមន្ត្រី បុគ្គលិក កំណត់យ៉ាងទាប ៧០ %

  ខ. ប្រាក់រង្វាន់សម្រាប់ពង្រឹងយន្តការផ្តល់សេវារដ្ឋបាលកំណត់យ៉ាងទាប១០% និងយ៉ាងច្រើន ៣០ %

## ៤. របៀបនៃការបែងចែក

ក. ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ខ្ទបត្ថម្ភជូនមន្ត្រី បុគ្គលិក

- ប្រាក់រង្វាន់សម្រាប់ឧបត្ថម្ភជូនមន្ត្រី បុគ្គលិកដែលផ្តល់សេវារដ្ឋបាលផ្ទាល់ កំណត់មិនឲ្យទាបជាង ២ដង និងមិនឲ្យច្រើនជាង ៣ដង នៃមន្ត្រី បុគ្គលិកផ្សេងៗទៀត
- ការបែងចែកប្រាក់រង្វាន់ ត្រូវគិតពីភាពសកម្ម ទំហំការងារ និង លទ្ធផលការងាររបស់មន្ត្រី បុគ្គលិកម្នាក់ៗ

## ៤. របៀបនៃការបែងចែក

ក. ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ខួបគ្រូម្ភជូនមន្ត្រី បុគ្គលិក

- មន្ត្រីទីប្រឹក្សា មន្ត្រីកិច្ចសន្យាដែលគាំទ្រដោយមូលនិធិរបស់ដៃគូអភិវឌ្ឍន៍នានា និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនត្រូវទទួលបានប្រាក់រង្វាន់នេះទេ
- អភិបាលស្រុក ត្រូវរៀបចំបញ្ជីឈ្មោះមន្ត្រី បុគ្គលិកដែលផ្តល់សេវាផ្ទាល់ និងមន្ត្រី បុគ្គលិកផ្សេងៗទៀត និងសំណើប្រាក់រង្វាន់ សម្រាប់មន្ត្រី បុគ្គលិកម្នាក់ៗ ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យសម្រេច។

## ៤. របៀបនៃការបែងចែក

ខ.ការប្រើប្រាស់ប្រាក់រង្វាន់សម្រាប់ពង្រឹងយន្តការផ្តល់សេវា

ចំណែកប្រាក់រង្វាន់នេះ សម្រាប់យកទៅគាំទ្របន្ថែមដល់កិច្ចប្រតិបត្តិការរដ្ឋបាល សម្ភារ និងមធ្យោបាយ ដូចជា៖

- សម្រាប់ពង្រឹងយន្តការ ឬអង្គភាពផ្តល់សេវា
- សម្រាប់ការគាំទ្រ និងការតាមដានត្រួត ពិនិត្យរបស់ក្រុមប្រឹក្សា
- សម្រាប់ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងការសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹង

# ៤. របៀបនៃការបែងចែក

- ប្រាក់រង្វាន់សម្រាប់មន្ទីរ អង្គភាព និងការិយាល័យជំនាញ
  - ✓ រដ្ឋបាលស្រុកមានតួនាទីត្រឹមតែបើកផ្តល់ចំណែកប្រាក់រង្វាន់ជូនដល់មន្ទីរ អង្គភាព និងការិយាល័យជំនាញតែប៉ុណ្ណោះ
  - ✓ ចំពោះប្រាក់រង្វាន់របស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ រដ្ឋបាលស្រុកត្រូវផ្ទេរតាមរយៈធនាគារACLEDA ដែលមានគណនីលេខ៖ 0001-0២-២២៤២៩១-១-១

**របៀបនៃការផ្ទេរប្រាក់រង្វាន់មកអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ**

# សូមអរគុណ!

